# ការប្រកាស សម្រាប់ជីវិត ដែលល្អបំផុត

" នោះបើរាស្ត្រអញ ដែលបានហៅ តាមឈ្មោះអញ គេបន្ទាបខ្លួន ហើយអធិស្ឋានរកមុខអញ ព្រមទាំងងាកបែរចេញពីផ្លូវអាក្រក់របស់គេ នោះអញនឹងស្តាប់ពីលើស្ថានសួគ៌ ហើយនឹងអត់ទោសអំពើបាបរបស់គេ ទាំងមើលស្រុកគេឲ្យជាផង "។ " នេះជាការអាថ៌កំបាំង៖ ព្រះគ្រីស្ទទ្រង់គង់ជាមួយខ្ញុំ ហើយទាំងអស់នេះ គឺជាចំណែកដែលអ្នកទទួលបានពីសិរីរុងរឿងរបស់ទ្រង់ "។ (២ របាក្សត្រ ៧: ១៤, កូល៉ុស ១: ២៧)

### ដោយសារសេចក្តីជំនឿ ដែលមាននៅក្នុងព្រះគ្រីស្ទ...

ខ្ញុំនឹងបោះបង់ភាពអំនួត ហើយឱបក្រសោបយកការបន្ទាបខ្លួនរបស់ព្រះគ្រីស្ទមកដាក់ក្នុងខ្លួនវិញ។(១)

ខ្ញុំនឹងបោះបង់ភាពច្រណែន ហើយឱបក្រសោបយកចិត្តស្កប់ស្កល់របស់ព្រះគ្រីស្ទមកដាក់ក្នុងខ្លួនវិញ។(២)

ខ្ញុំនឹងបោះបង់ភាពលោភលន់ ហើយឱបក្រសោបយកចិត្តទូលាយរបស់ព្រះគ្រីស្ទមកដាក់ក្នុងខ្លួនខ្ញុំវិញ។ (៣)

ខ្ញុំនឹងបោះបង់ភាពមិនឆ្អែតឆ្អន់ ហើយឱបក្រសោបយកភាពចេះប្រមាណរបស់ព្រះគ្រីស្ទមកដាក់ក្នុងខ្លួនខ្ញុំវិញ។ (៤)

ខ្ញុំនឹងបោះបង់តណ្ហា ភាពត្រេកត្រអាល ហើយឱបក្រសោបយកភាពបរិសុទ្ធ របស់ព្រះគ្រីស្ទគឺនៅមកដាក់ក្នុងខ្លួនខ្ញុំវិញ។ (៥)

ខ្ញុំនឹងបោះបង់ភាពខឹង ហើយឱបក្រសោបយកភាពមេត្តាករុណារបស់ព្រះគ្រីស្ទមកដាក់ក្នុងខ្លួនខ្ញុំវិញ។ (៦)

ខ្ញុំនឹងបោះបង់ភាពខ្ជិលច្រអូល ហើយឱបក្រសោបយកភាពជាអ្នកបំរើរបស់ព្រះគ្រីស្ទមកដាក់ក្នុងខ្លួនខ្ញុំវិញ។ (៧)

ខ្ញុំនឹងបោះបង់ការនិយាយបង្ខូច ហើយឱបក្រសោបយកព្រះពររបស់ព្រះគ្រីស្ទមកដាក់ក្នុងខ្លួនខ្ញុំវិញ។ (៨)

[១] **យ៉ាកុប ៤: ៦** តែទ្រង់ផ្តល់ព្រះគុណមកកាន់តែខ្លាំងឡើង ហេតុនោះបានជាទ្រង់មានព្រះបន្ទូលថា «ព្រះទ្រង់ទាស់ទទឹងនឹងពួកមានឫកធំ តែទ្រង់ផ្តល់ព្រះគុណមកពួករាបសាវិញ»។

[២]**សាស្ត្រា ៤: ៤** រួចយើងបានឃើញអស់ទាំងការនឿយហត់ និងគ្រប់ការដែលធ្វើបានដោយស្រួលថា ជាហេតុនាំឲ្យអ្នកជិតខាងមានចិត្តច្រណែនដល់គ្នានឹងគ្នា នេះក៏ជាការឥតមានទំនង ហើយជាអសារឥតការទេទេ។
**១ធីម៉ូថេ ៦: ៦** តែការគោរពប្រតិបត្តិដល់ព្រះ ដែលមានទាំងចិត្តស្កប់ស្កល់ផង នោះជាកំរៃ១យ៉ាងធំមែន ។

[៣]**អេភេសូរ ៥: ៥** ដ្បិតអ្នករាល់គ្នាដឹងថា គ្មានមនុស្សកំផិត ឬស្មោកគ្រោក ឬលោភ គឺជាមនុស្សថ្វាយបង្គំរូបព្រះ ដែលនឹងគ្រងមរដកក្នុងនគរនៃ ព្រះគ្រីស្ទ ហើយនៃព្រះផងបានឡើយ។
**សុភាសិត ២១: ២៦** មានគេដែលលោភលន់រាល់តែថ្ងៃជានិច្ច តែឯមនុស្សសុចរិត គេចែកចាយវិញ ឥតសំចៃទុកអ្វីឡើយ។

[៤]**សុភាសិត ២៣: ២០-២១** កុំឲ្យនៅកណ្តាលពួកអ្នកប្រមឹកស្រា ឬក្នុងពួកល្មោភស៊ីឡើយ ២១ ដ្បិតមនុស្សប្រមឹក និងមនុស្សល្មោភនឹងទៅជាក្រ ហើយសេចក្តីងុយងោកនឹងនាំឲ្យស្លៀកពាក់កណ្តាច។

[៥]**យ៉ូប ៣: ១១** ខ្ញុំបានតាំងសញ្ញានឹងភ្នែកខ្ញុំហើយ ដូច្នេះ ធ្វើដូចម្តេចឲ្យខ្ញុំមើលស្ត្រីក្រមុំដោយចាប់ចិត្តបាន។
**ម៉ាថាយ ៥: ៦** មានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត។

[៦]**១កូរិនថូស ១៣: ៤** ឯសេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្តីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង។

[៧]**រ៉ូម ១២: ១១** ខាងឯសេចក្តីឧស្សាហ៍ នោះកុំឲ្យខ្ជិលឡើយ ខាងឯវិញ្ញាណ នោះក៏ចូរព្យាយាមចុះ ដោយខំប្រឹងបំរើព្រះអម្ចាស់។

[៨]**១កូរិនថូស ១៣: ៤** យើងខ្ញុំធ្វើការនឿយហត់នឹងដៃយើង កាលណាគេជេរ នោះយើងខ្ញុំឲ្យពរវិញ កាលណាគេបៀតបៀន នោះយើងខ្ញុំទ្រាំទ្រ។

**បកប្រែដោយ: ONE -2- ONE CAMBODIA**
**អាស័យដ្ឋាន: # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC11